គណៈកម្មាធិការប្រឆាំងទារុណកម្ម

## បញ្ជីសំណួរទាក់ទងនឹងការពិនិត្យរបាយការណ៍តាមពេលកំណត់លើកទី ៣ របស់ប្រទេសកម្ពុជា ដែលបានអនុម័តដោយគណៈកម្មាធិការក្នុងសម័យប្រជុំរបស់ខ្លួនលើកទី ៤៩ (ចាប់ពីថ្ងៃទី ២៩ ខែតុលាដល់ថ្ងៃទី ២៣ ខែវិច្ឆិកាឆ្នាំ ២០១២)[1]

## ឯកសារមុនពេលស្តាពរដែលមិនទាន់បានកែសម្រួល

ព័ត៌មានជាក់លាក់ទាក់ទងនឹងការអនុវត្តន៍មាត្រា ១ ដល់មាត្រា ១៦ នៃអនុសញ្ញានេះរាប់ទាំងព័ត៌មាន ស្តីពីអនុសាសន៍នានាកាលពីលើកមុនរបស់គណៈកម្មាធិការ[2]

មាត្រា ១ និងមាត្រា ៤

១. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១១ និង១៥) សូមចង្អុលបង្ហាញថាតើមានបទឧក្រិដ្ឋទារុណកម្មជាក់លាក់ណាមួយ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ព្រហ្មទណ្ឌដែរ ឬទេ ហើយថាតើវាឆ្លុះបញ្ចាំងនូវនិយមន័យនៃអំពើទារុណកម្មដូចដែលបានចែងក្នុងមាត្រា ១ នៃអនុសញ្ញានេះដែរ ឬយ៉ាងណា។ សូមផ្តល់នូវអត្ថបទពេញលេញនៃបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ដែលទាក់ទងនឹងបទល្មើសដូចជាការប៉ុនប៉ងធ្វើទារុណកម្ម ការញុះញង់ ឬការព្រមព្រៀងធ្វើទារុណកម្ម ឬការបញ្ជាឲ្យធ្វើទារុណកម្មពីជនដែលកំពុងកាន់អំណាច ដោយមានចែងច្បាស់លាស់នូវទោសបញ្ញត្តិសម្រាប់បទល្មើសនីមួយៗ ព្រមទាំងចង្អុលបង្ហាញប្រសិនបើរដ្ឋភាគីបានអនុម័តផែនការកំណត់ទោសសំរាប់អំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ដែលប្រព្រឹត្តឡើងដោយមន្ត្រី ដើម្បីធានាថាអ្នកដែលត្រូវបានផ្តន្ទាទោស ត្រូវតែបានកាត់ទោសសមស្រប។[3]

២. ដូចដែលគណៈកម្មាធិការបានលើកជាសំណើក្នុងអនុសាសន៍កាលពីមុនរបស់ខ្លួន (កថាខណ្ឌ ១០) សូមផ្តល់នូវពតិមានស្តីពីវិធានការនានាដែលបានចាត់ឲ្យមានឡើង ដើម្បីធានាឲ្យមានការអនុវត្តន៍

[1] បញ្ជីសំណួរនេះត្រូវបានអនុម័តដោយគណៈកម្មាធិការក្នុងសម័យប្រជុំរបស់ខ្លួនលើកទី ៤៩ យោងតាមនីតិវិធីជម្រើសថ្មី ដែលត្រូវបានបង្កើតដោយគណៈកម្មាធិការក្នុងសម័យប្រជុំរបស់ខ្លួនលើកទី ៣៨ ឲ្យមានឡើងសំរាប់ត្រៀមរៀបចំ និងអនុម័តបញ្ជីសំណួរ ដែលត្រូវដាក់ជូនរដ្ឋភាគីទាំងឡាយ មុនពេលរដ្ឋភាគីនីមួយៗបញ្ជូនរបាយការណ៍តាមកាលកំណត់របស់ខ្លួន។ ចម្លើយនានារបស់រដ្ឋភាគីតបទៅនឹងបញ្ជីសំណួរនេះ នឹងបង្កើតបានជារបាយការណ៍របស់ខ្លួនតាមមាត្រា ១៩ នៃអនុសញ្ញា។

[2] លេខកថាខ័ណ្ឌក្នុងវង់ក្រចកសំដៅដល់អនុសាសន៍នានាកាលពីលើកមុន ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការ និងបោះពុម្ពផ្សាយក្រោមចំណងជើង (និមិត្តសញ្ញា) CAT/C/KHM/CO/2 ។

[3] CAT/C/SR.968 កថាខ័ណ្ឌ ៦ ៤៣ និង៦៦។

ពេញលេញនូវបទប្បញ្ញត្តិនៃអនុសញ្ញានេះនៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន ជាពិសេសលើករណី នៃការអនុវត្តន៍អនុសញ្ញាដោយផ្ទាល់ដោយតុលាការជាតិ ប្រសិនបើមាន។

៣. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើការព្រួយបារម្ភ ដែលបានបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន ស្តីពីការបង្ហាញឲ្យឃើញនូវបរិយាកាសនិទ្ទណ្ឌភាពនៅក្នុងរដ្ឋភាគី (កថាខណ្ឌទី១៥) សូមផ្តល់នូវពត៌មានស្តីពីការចាត់វិធានការដោយរដ្ឋភាគីក្នុងការធានាថា គ្មាននិទ្ទណ្ឌភាពចំពោះអំពើទារុណកម្ម និងប្រព្រឹត្តកម្មមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ សូមផ្តល់ផងដែរនូវពត៌មានជាស្ថិតិ ទាក់ទងនឹងការចោទប្រកាន់ទៅលើមន្ត្រី ពីបទប្រព្រឹត្តអំពើទារុណកម្ម ប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន និងបទល្មើសដែលពាក់ព័ន្ធ ចាប់តាំងពីបានពិនិត្យរបាយការណ៍កាលពីលើកមុន ដោយបញ្ជាក់ពីឋានៈ និងឋានន្តរស័ក្តិរបស់ចុងចោទនីមួយៗ និងមាត្រាច្បាប់ដែលចុងចោទត្រូវបានចោទប្រកាន់ ហើយថាតើចុងចោទត្រូវបានផ្តន្ទាទោស និងកាត់ទោសដែរ ឬយ៉ាងណា។

## មាត្រា ២[4]

៤. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៥) ដោយកត់សម្គាល់នូវការចោទប្រកាន់ស៊ីសង្វាក់គ្នាជាច្រើន ដែលកំពុងបន្តកើតមានពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើជនជាប់ឃុំ នៅក្នុងប្រទេសរបស់រដ្ឋភាគី ជាពិសេសគឺនៅតាមអង្គភាពនគរបាល សូមរៀបរាប់អំពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឲ្យមានឡើង ដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម ព្រមទាំងប្រព្រឹត្តកម្មមិនគប្បីទៅលើជនជាប់ឃុំនៅតាមទីកន្លែងឃុំខ្លួន។ សូមចង្អុលបង្ហាញឲ្យបានជាក់លាក់ ថាតើរដ្ឋភាគីបានប្រកាសគោលនយោបាយ ដើម្បីលុបបំបាត់ការធ្វើទារុណកម្ម ឬយ៉ាងណា និងពិពណ៌នាពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឲ្យមានឡើង ដើម្បីឃ្លាំមើលគ្រប់ដំណាក់កាលសួរយកចម្លើយដោយមន្ត្រីនគរបាល ឧទាហរណ៍តាមមធ្យោបាយថតវីឌីអូ ឬថតសម្លេង។

[4] បញ្ហាទាំងឡាយដែលបានលើកឡើងតាមមាត្រា ២ អាចពាក់ព័ន្ធផងដែរនឹងមាត្រាផ្សេងៗគ្នានៃអនុសញ្ញា រាប់ទាំងប៉ុន្តែមិនកំណត់ត្រឹមតែមាត្រា ៦ ឡើយ។ ដូចសេចក្តីពន្យល់ទូទៅលេខ ២ ត្រង់កថាខ័ណ្ឌ ៣ ចែងថា "កាតព្វកិច្ចដើម្បីបង្ការអំពើទារុណកម្មក្នុងមាត្រា ២ មានលក្ខណៈទូលំទូលាយ។ កាតព្វកិច្ចដើម្បីបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ចាប់ពីពេលនេះទៅហៅថា "ប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន") តាមមាត្រា ១៦ កថាខ័ណ្ឌ ១ គឺមិនអាចបំបែកចេញពីគ្នាបាន អាស្រ័យគ្នាទៅវិញទៅមក និងមានភាពពាក់ព័ន្ធគ្នាទៅវិញទៅមក។ កាតព្វកិច្ចដើម្បីបង្ការប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន តាមការអនុវត្តន៍ជាក់ស្តែងជាន់គ្នា ហើយភាគច្រើនក៏ប្រលាំគ្នានឹងកាតព្វកិច្ចដើម្បីបង្ការអំពើទារុណកម្មផងដែរ (...)។ តាមនិយមន័យខ័ណ្ឌសីមារវាងប្រព្រឹត្តកម្មមិនគប្បី និងអំពើទារុណកម្ម មិនមានលក្ខខណៈច្បាស់លាស់ឡើយ" តាមការអនុវត្តន៍ជាក់ស្តែង។ សូមមើលជំពូក ៥ នៃសេចក្តីពន្យល់ទូទៅដូចគ្នានេះបន្ថែមទៀត។

៥.	បន្ទាប់ពីបានពិនិត្យពិចារណាទៅលើការព្រួយបារម្ភ ដែលបានបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន ទាក់ទងនឹងការរីករាលដាលនៃអំពើពុករលួយ និងជាលក្ខណៈប្រព័ន្ធ ដែលប៉ះពាល់ដល់ចៅក្រម តុលាការ មន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអនុវត្តច្បាប់ផ្សេងៗទៀត (កថាខណ្ឌ ១២) សូមផ្តល់នូវពតិមានទាក់ទងនឹងចំណាត់ការក្នុងការលុបបំបាត់អំពើពុករលួយ ជាពិសេសៈ

(ក)	ថាតើអង្គភាពប្រឆាំងអំពើពុករលួយ បានដំណើរការពេញលេញ ឬយ៉ាងណា ប្រសិនបើមានដំណើរការពេញលេញ សូមផ្តល់នូវពតិមានអំពីបុគ្គលិករបស់អង្គភាពនោះ ព្រមទាំងវិធានការនានាក្នុងការធានាឯករាជ្យភាពរបស់ខ្លួនពីស្ថាប័នទាំងឡាយ ដែលអង្គភាពនេះទទួលភារកិច្ចក្នុងការឃ្លាំមើល និងសូមផ្តល់នូវទិន្នន័យដែលអង្គភាពនេះទទួលបាន ស្តីពីចំនួននៃពាក្យបណ្តឹងដែលបានទទួល ការស៊ើបអង្កេតដែលបានធ្វើឡើង និងទិន្នន័យស្តីពីការផ្តន្ទាទោស។

(ខ)	ចំនួនមន្ត្រីរាជការដែលត្រូវបានផ្តន្ទាទោស ពីបទទាក់ទងនឹងអំពើពុករលួយ ចាប់តាំងពីបានពិនិត្យរបាយការណ៍លើកចុងក្រោយ ដោយបញ្ជាក់ពីឋានន្តរស័ក្តិ និងទោសដែលត្រូវទទួល[5]។

(គ)	វិធានការនានាដើម្បីលុបបំបាត់ទម្លាប់អនុវត្តន៍របស់មន្ត្រីនគរបាល ដែលទទួលកម្រៃជាទឹកប្រាក់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

៦.	ដូចដែលគណៈកម្មាធិការបានផ្តល់អនុសាសន៍ (កថាខណ្ឌ ១៥) សូមបញ្ជាក់បង្ហាញប្រសិនបើរដ្ឋភាគីបានអនុម័តច្បាប់ ចាប់តាំងពីបានពិនិត្យរបាយការណ៍កាលពីលើកមុន ដែលហាមឃាត់ដាច់ខាតមិនឲ្យប្រើប្រាស់កាលៈទេសៈពិសេស មកធ្វើជាលេសក្នុងការធ្វើទារុណកម្ម និងអនុលោមតាមមាត្រា ២(២) នៃអនុសញ្ញា។ ប្រសិនបើបានអនុម័តសូមផ្តល់អត្ថបទច្បាប់នេះ។ ប្រសិនបើមិនទាន់បានអនុម័តទេនោះ សូមបញ្ជាក់ថាតើរដ្ឋភាគីមានបំណងអនុម័តច្បាប់នេះ ឬយ៉ាងណា។

៧.	បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៣) សូមផ្តល់នូវព័ត៌មានស្តីពីវិធានការនានា ដែលបានចាត់ឲ្យមានឡើងដើម្បីធានាការពារនូវឯករាជ្យភាពតុលាការស្របតាមបទដ្ឋានអន្តរជាតិ។ សូមរៀបរាប់ឲ្យបានពិស្តារចំពោះវិធានការទាំងឡាយ ដែលបានចាត់ឲ្យមានឡើងដើម្បីៈ

[5] CAT/C/SR.968 កថាខ័ណ្ឌ ៨ ១២ ៤៥ និង ៧២។ A/HRC/18/47 កថាខ័ណ្ឌ ៤៣។ A/HRC/13/4 កថាខ័ណ្ឌ ១៨ និង ៨២ (៣៥) និង (៣៦)។

(ក) អនុម័តច្បាប់ដែលមានគោលបំណងធ្វើកំណែទម្រង់ប្រព័ន្ធតុលាការ [6]រួមទាំងការប្រឹក្សាយោបល់ ដែលបានធ្វើឡើងជាមួយនឹងសង្គមស៊ីវិល និងអង្គការសហប្រជាជាតិស្តីពីសេចក្តីព្រាងច្បាប់។

(ខ) អនុវត្តន៍នូវអនុសាសន៍ទាំងឡាយ ដែលបានធ្វើដោយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា (A/HRC/15/46, កថាខណ្ឌ ៦៦-៧១)[7]។

៨. សូមពិពណ៌នាពីការខិតខំប្រឹងប្រែងដែលបានធ្វើឡើង (ក) ដើម្បីផ្តល់នូវកិច្ចសហការ និងជំនួយចាំបាច់ទាំងអស់ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងដើម្បីធានាថាសហចៅក្រមស៊ើបអង្កេត និងបុគ្គលិកជាតិ និងអន្តរជាតិទាំងឡាយនៅ អ.វ.ត.ក អាចបំពេញការងារដោយសេរីមិនស្ថិតក្រោមការជ្រៀតជ្រែកខាងនយោបាយ និង (ខ) ដើម្បីធានានូវការស៊ើបអង្កេតដោយមិនលំអៀង និងមានប្រសិទ្ធភាពទៅលើការចោទប្រកាន់ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងសម័យខ្មែរក្រហមនៅក្នុងសំណុំរឿង ០០៣ និង ០០៤។

៩. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថា-ខណ្ឌ ១៨) សូមផ្តល់ព័ត៌មានស្តីពីវិធានការដែលបានចាត់ឲ្យមានឡើង ដើម្បីធានាថា (ក) ជនជាប់ឃុំទាំងអស់ត្រូវតែទទួលបាននូវកិច្ចធានាការពារជាមូលដ្ឋានតាមផ្លូវច្បាប់ និងតាមការអនុវត្តន៍ជាក់ស្តែងចាប់តាំងពីពេលឃាត់ខ្លួន/ឃុំខ្លួនលើកដំបូង (ខ) គ្រប់ជនដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបាននូវ៖

(ក) សិទ្ធិមានមេធាវីជាបន្ទាន់ចាប់តាំងពីពេលពួកគេ ត្រូវបានដកហូតសេរីភាពលើកដំបូងរហូតដល់ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលជំនុំជម្រះក្តី និងដំណាក់កាលប្តឹងឧទ្ធរណ៍។ សូមផ្តល់នូវទិន្នន័យពីចំនួនមេធាវីដែលត្រូវបានទទួលជាសមាជិកគណៈមេធាវី ចំនួនមេធាវីដែលកំពុងប្រកបវិជ្ជាជីវៈ ចំនួនមេធាវីជំនួយផ្នែកច្បាប់ ចំនួនសំណុំរឿងដែលត្រូវការជំនួយផ្នែកច្បាប់ ដោយបែងចែកទៅតាមខេត្ត។ សូមចង្អុលបង្ហាញពីវិធានការនានា ដែលបានចាត់ឲ្យមានឡើងដោយរដ្ឋភាគី ដើម្បីបង្កើននូវការផ្គត់ផ្គង់សេវាជំនួយផ្នែកច្បាប់ រាប់ទាំងតាមរយៈការបង្កើនចំនួនមេធាវីជំនួយផ្នែកច្បាប់ ហើយនឹងសូមចង្អុលបង្ហាញនូវផែនការជាទូទៅបន្ថែមទៀត ដើម្បីបង្កើតនូវប្រព័ន្ធជំនួយផ្នែកច្បាប់យ៉ាងទំលំទំលាយមួយនៅក្នុងប្រទេស។

---

[6] CAT/C/SR.968 កថាខ័ណ្ឌ ១១ និង ៦៧។

[7] A/HRC/15/46 កថាខ័ណ្ឌ ១៩ - ២៩ ។

(ខ) សិទ្ធិទទួលបានការពិនិត្យសុខភាពដោយឯករាជ្យ ពីគ្រូពេទ្យតាមការជ្រើសរើសដោយខ្លួនឯង ចាប់តាំងពីពេលដកហូតសេរីភាពដំបូង។

(គ) សិទ្ធិក្នុងការផ្តល់ដំណឹងដល់សាច់ញាតិអំពីការឃុំខ្លួនរបស់ពួកគេ។

(ឃ) សិទ្ធិក្នុងការប្រាប់ឲ្យដឹងអំពីសិទ្ធិទាំងឡាយ និងបទចោទដែលប្រឆាំងនឹងខ្លួន ព្រមទាំងការនាំមកបង្ហាញខ្លួនភ្លាមៗនៅចំពោះមុខចៅក្រម។

១០. សូមចង្អុលបង្ហាញអំពី (ក) វិធានការដែលមានស្រាប់ក្នុងការធានាថា គ្រប់ការឃុំខ្លួនបុគ្គលត្រូវតែបានចុះបញ្ជី ចាប់តាំងពីពេលពួកគេត្រូវបានដកហូតសេរីភាពដំបូង (ខ) នីតិវិធីដែលមានស្រាប់ដើម្បីធ្វើអធិការកិច្ចលើកំណត់ហេតុឃាត់ខ្លួនតាមពេលកំណត់នៅទីកន្លែងឃាត់ខ្លួន/ឃុំខ្លួន និង (គ) វិធីដែលសមាជិកគ្រួសារ និងមេធាវីអាចពិនិត្យមើល និងទទួលបាននូវកំណត់ហេតុឃាត់/ឃុំខ្លួន។

១១. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២១) សូមផ្តល់នូវព័ត៌មានទាក់ទងទៅនឹង៖

(ក) វិធានការទាំងឡាយដែលបានចាត់ឲ្យមានឡើង ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាលើយេនឌ័រ និងការរំលោភបំពានលើស្ត្រីភេទ និងកុមាររួមទាំងការរំលោភសេពសន្ថវៈ។

(ខ) ស្ថិតិអំពីចំនួនពាក្យបណ្តឹងដែលបានទទួលក្នុងអំឡុងពេលធ្វើរបាយការណ៍ ពីបទអំពើហឹង្សាលើផ្លូវភេទ រួមមានការរំលោភសេពសន្ថវៈ ដោយបែងចែកទៅតាមអង្គភាពដែលទទួលបានបណ្តឹង ក៏ដូចជាស្ថិតិពីចំនួននៃការស៊ើបអង្កេត ដែលបានធ្វើឡើងទៅលើករណីបែបនេះ ចំនួនសំណុំរឿងដែលបានចោទប្រកាន់ ចំនួនករណីដែលបានផ្តន្ទាទោស បទចោទប្រកាន់ និងការកាត់ទោសនៅក្នុងសំណុំរឿងនីមួយៗ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ហើយនឹងចំនួនសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវបានអនុវត្តន៍បន្ទាប់ពីការវិនិច្ឆ័យទោស (សាលក្រម)។[8]

(គ) យន្តការដែលបានបង្កើតឡើងដើម្បីសម្រួលដល់ការផ្តល់នូវការថែទាំខាងចិត្តសាស្ត្រ និងវេជ្ជសាស្ត្រ និងសូមផ្តល់នូវទិន្នន័យស្តីពីការជួសជុលសំណង ដែលបានផ្តល់ទៅឲ្យជនរងគ្រោះក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ។

[8] CRC/C/KHM/CO/2-3 កថាខ័ណ្ឌ ៧១-៧២។ CAT/C/SR.968 កថាខ័ណ្ឌ ៥២ និង ៦០។ A/HRC/16/44/Add.3 កថាខ័ណ្ឌ ៦២។

(ឃ) វិធានការនានាដែលបានចាត់ឲ្យមានឡើង ដើម្បីធានាភាពប្រសើរឡើងនូវយុត្តិធម៌ ដែលស្ត្រីទទួលរងអំពើហិង្សាទទួលបាន និងលើកឡើងពីទម្លាប់អនុវត្តន៍ដោះស្រាយក្រៅផ្លូវតុលាការ ចំពោះការរំលោភសេពសន្ថវៈ។

១២. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២២) សូមផ្តល់ព័ត៌មានទាក់ទងទៅនឹងចំណាត់ការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសគឺស្ត្រី និងកុមារ រាប់ទាំងវិធានការនានាដើម្បីៈ

(ក) បង្កើតនូវលក្ខខ័ណ្ឌដែលជនរងគ្រោះពីអំពើជួញដូរមនុស្ស អាចប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងការដាក់ពាក្យបណ្តឹង។ សូមបង្ហាញចំនួនពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដែលទទួលបានក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ ហើយនឹងចំនួននៃការស៊ើបអង្កេតទាំងអស់ ដែលបានធ្វើទៅលើការចោទប្រកាន់ពីបទជួញដូរមនុស្ស ចំនួននៃបទចោទប្រកាន់ ហើយថាតើបទចោទប្រកាន់ទាំងនោះត្រូវបានផ្តន្ទាទោស ឬទេ ហើយប្រសិនបើត្រូវបានផ្តន្ទាទោស សូមបញ្ជាក់ពីទោសដែលបានសម្រេចនៅក្នុងរឿងក្តីនីមួយៗ។

(ខ) ផ្តល់ការការពារដល់ជនរងគ្រោះពីអំពើជួញដូរមនុស្ស ហើយនឹងធានាថាជនរងគ្រោះអាចទទួលបាននូវសេវាវេជ្ជសាស្ត្រ សង្គមកិច្ច ស្តារនីតិសម្បទា និងសេវាច្បាប់ រាប់ទាំងសេវាប្រឹក្សាយោបល់តាមភាពសមស្រប។ សូមបញ្ជាក់ពីចំនួនជនរងគ្រោះដែលទទួលបានសេវាបែបនេះ ព្រមទាំងទិន្នន័យទាក់ទងនឹងការជួសជុលសំណងទាំងឡាយ ដែលតុលាការបានផ្តល់ដល់ជនរងគ្រោះ។[9]

១៣. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍ទាំងឡាយរបស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២៩) និងការទទួលយកអនុសាសន៍ដោយរដ្ឋភាគី ដែលបានធ្វើឡើងនៅពេលកំពុងពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមកាលកំណត់ (A/HRC/13/4 កថាខណ្ឌ ៨២.៧) សូមពិពណ៌នាពីវិធានការក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យថ្នាក់ជាតិមួយ អនុលោមតាមគោលការណ៍ទីក្រុងប៉ារីស។[10]

១៤. សូមផ្តល់ព័ត៌មានអំពីចំណាត់ការដែលបានចាត់ឲ្យមានឡើង ដើម្បីបង្កើតយន្តការបង្ការទារុណកម្មឯករាជ្យថ្នាក់ជាតិ (NPM) ដោយមានអណត្តិការងារ និងធនធានចាំបាច់ក្នុងការបំពេញកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តកម្មមកលើខ្លួន ឬ

[9] CRC/C/KHM/CO/2-3 កថាខ័ណ្ឌ ៧៣ - ៧៤។ CAT/C/SR.968 កថាខ័ណ្ឌ ២៥ - ៣១។

[10] A/HRC/18/47 កថាខ័ណ្ឌ ៩៦។ CERD/C/KHM/CO/8-13 កថាខ័ណ្ឌ ១៥។

ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដោយកត់សម្គាល់នូវការព្រួយបារម្ភ ដែលបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ៣០) [11] ដែលថាគណៈកម្មាធិការអន្តររដ្ឋាភិបាល ដែលបានបង្កើតឡើងដោយរដ្ឋភាគីក្នុងខែសីហាឆ្នាំ ២០០៩ មិនបានអនុវត្តទៅតាមលក្ខខណ្ឌតម្រូវនានារបស់ពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំទារុណកម្មឡើយ។ សូមពិពណ៌នាអំពីភាពជឿនលឿនក្នុងការអនុម័តច្បាប់ ស្តីពីការបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិមួយដែលឯក - រាជ្យ។ សូមបង្ហាញបញ្ជាក់ផងដែរប្រសិនបើរដ្ឋភាគី ពិនិត្យពិចារណាក្នុងការផ្សព្វផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការបង្ការទារុណកម្មជាសារធារណៈ បន្ទាប់ពីបានបំពេញទស្សនកិច្ចត្រួតពិនិត្យរបស់ខ្លួននៅអំឡុងខែធ្នូឆ្នាំ ២០០៩។

១៥. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថា - ខណ្ឌ ៣១) សូមផ្តល់នូវព័ត៌មានស្តីពី៖

(ក) វិធានការទាំងឡាយដែលបានចាត់ឲ្យមានឡើង ដើម្បីធានាថាអង្គការសង្គមស៊ីវិល រាប់ទាំងអង្គការក្រៅរដ្ឋាភិបាល មិនត្រូវទទួលរងការដាក់កំហិតពាក់ព័ន្ធនឹងការបង្កើត ឯករាជ្យភាព និងដំណើការរបស់ពួកគេឡើយ ហើយពួកគេត្រូវបានការពារពីការបំភិតបំភ័យ ឬអំពើហឹង្សាដែលបណ្តាលមកពីសកម្មភាពរបស់ពួកគេ។

(ខ) របាយការណ៍នានាដែលមានបទប្បញ្ញត្តិជាក់លាក់នៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល អាចរារាំង និងដាក់កំហិតលើការងារស្របច្បាប់របស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការលើកស្ទួយសិទ្ធិមនុស្ស ដូចដែលអ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស បាននិយាយយោងដល់នៅក្នុងលិខិតអះអាងរួមមួយច្បាប់ចុះថ្ងៃទី ១៣ ខែឧសភាឆ្នាំ ២០១១ ។[12]

១៦. ដូចដែលគណៈកម្មាធិការបានផ្តល់អនុសាសន៍កាលពីលើកមុន (កថាខណ្ឌ ១២ និង១៦) សូមបញ្ជាក់ថាតើរដ្ឋភាគីមានបានបង្កើតកម្មវិធីការពារសាក្សី និងអ្នករិះគន់ឥតសំចៃមាត់ ដែលមានសមត្ថ - ភាពរក្សាការសម្ងាត់ចំពោះអ្នកដែលអះអាងពីបទល្មើស រួមមានបទល្មើសពុករលួយ ទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ហើយនឹងផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់ឲ្យកម្មវិធីនេះ អាចដំណើរការដោយមានប្រសិទ្ធភាព ឬយ៉ាណា។

[11] A/HRC/18/47 កថាខ័ណ្ឌ ៤៦ - ៤៧។ CAT/C/SR.968 កថាខ័ណ្ឌ ២១ - ២៣។

[12] A/HRC/20/27/Add.3 កថាខ័ណ្ឌ ៥៥ - ៦១ ។ A/HRC/18/46 កថាខ័ណ្ឌ ២៥ - ៣១។ A/HRC/18/47 កថាខ័ណ្ឌ ១៩ - ២៩។

មាត្រា ៣

១៧. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២៥) សូមបង្ហាញបញ្ជាក់ (ក) ថាតើរដ្ឋភាគីមានបានហាមឃាត់នូវការបណ្តេញចេញ បញ្ជូនត្រលប់ ឬធ្វើបត្យាប័នបុគ្គលណាមួយទៅកាន់រដ្ឋមួយផ្សេងទៀត នៅពេលដែលមានមូលដ្ឋានគ្រប់គ្រាន់អាចជឿជាក់បានថា ជននោះអាចនឹងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដែលអាចជាកម្មវត្ថុនៃការធ្វើទារុណកម្ម[13] និង (ខ) ថាតើរដ្ឋភាគីបានអនុម័តច្បាប់ស្តីពីការធានាការពារសិទ្ធិរបស់ជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោនគ្រប់រូប រួមទាំងកុមារដែលគ្មានឪពុកម្តាយអមដំណើរ ហើយនឹងតាមច្បាប់ និងតាមការអនុវត្តន៍ជាក់ស្តែង មានបានផ្តល់កិច្ចធានាការពារតាមនីតិវិធីដល់បុគ្គល ដែលប្រឈមនឹងការបណ្តេញចេញ ការបញ្ជូនត្រលប់ ឬការធ្វើបត្យាប័នដែរ ឬយ៉ាងណា។

១៨. សូមផ្តល់ព័ត៌មានទាក់ទងទៅនឹង (ក) ច្បាប់ គោលនយោបាយ និងការអនុវត្តន៍ស្តីពីការគ្រប់គ្រងការចុះបញ្ជី និងដំណើរការដាក់ពាក្យសុំសិទ្ធិជ្រកកោន ដែលត្រូវបានធ្វើឡើងពីទីកន្លែងឃុំខ្លួន រួមមានមណ្ឌលឃាត់ខ្លួនជនអន្តោប្រវេសន្ត និងពន្ធនាគារ ហើយនឹង (ខ) ពេលវេលាជាមធ្យមសំរាប់ដំណើរការដាក់ពាក្យសុំសិទ្ធិជ្រកកោន។

១៩. សូមផ្តល់ទិន្នន័យទាក់ទងទៅនឹងសំណើបត្យាប័នទាំងអស់ ដែលរដ្ឋភាគីបានទទួលក្នុងកំឡុងពេលធ្វើរបាយការណ៍ ដោយបញ្ជាក់ពីរដ្ឋស្នើសុំបត្យាប័ន និងបង្ហាញថាតើរដ្ឋណាខ្លះត្រូវបានផ្តល់ការយល់ព្រម ហើយរដ្ឋណាខ្លះត្រូវបានបដិសេធ និងសូមប្រាប់ពីហេតុផលក្នុងការបដិសេធនោះ។ សូមផ្តល់ព័ត៌មានស្តីពីកិច្ចព្រមព្រៀងទាំងឡាយ ដែលរដ្ឋភាគីបានយល់ព្រមចុះ ទាក់ទងទៅនឹងការបញ្ជូនត្រលប់ជនស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន ឬទាក់ទងទៅនឹងការធានារ៉ាប់រងតាមផ្លូវទូត។

២០. សូមផ្តល់នូវទិន្នន័យដោយបែងចែកតាមអាយុ ភេទ និងជាតិសាសន៍ ពាក់ព័ន្ធទៅនឹងៈ

(ក) គ្រប់បត្យាប័ន ការបញ្ជូនត្រលប់ និងការបណ្តេញចេញ ដែលបានធ្វើឡើងដោយរដ្ឋភាគី ដោយគិតចាប់តាំងពីបានពិនិត្យរបាយការណ៍តាមពេលកំណត់កាលពីលើកមុន ដោយចង្អុលបង្ហាញពីរដ្ឋណាខ្លះ ដែលបុគ្គលត្រូវបានបញ្ជូនត្រលប់ទៅវិញ។

[13] A/HRC/WG.6/6/KHM/3 កថាខ័ណ្ឌ ៥៩។

(ខ) គ្រប់ពាក្យសុំសិទ្ធិជ្រកកោនដែលត្រូវបានចុះបញ្ជី ដោយបែងចែកទៅតាមប្រទេសកំណើត។

(គ) ចំនួនបុគ្គលសុំសិទ្ធិជ្រកកោនពីទីកន្លែងឃុំខ្លួន។

(ឃ) ចំនួនបុគ្គលដែលពាក្យសុំសិទ្ធិជ្រកកោនរបស់ពួកគេ ត្រូវបានយល់ព្រមផ្តល់ឲ្យដោយបែងចែកទៅតាមប្រទេសកំណើត និង

(ង) ចំនួនបុគ្គលដែលពាក្យសុំសិទ្ធិជ្រកកោនរបស់ពួកគេ ត្រូវបានយល់ព្រមផ្តល់ឲ្យដោយផ្អែកលើហេតុផលជាក់លាក់ថា បុគ្គលនោះត្រូវបានគេធ្វើទារុណកម្ម ឬអាចនឹងត្រូវទទួលរងការធ្វើទារុណកម្ម ប្រសិនបើបញ្ជូនត្រលប់ទៅវិញ។

២១. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២៤) សូមផ្តល់ព័ត៌មានអំពីអ្នកសុំសិទ្ធិជ្រកកោន ជាជនជាតិដើមភាគតិចម៉ុងតាញ៉ាចំនួន ៦៧៤ នាក់ និងអ្នកសុំសិទ្ធិជ្រកកោនជនជាតិអ៊ុយហ្គ័រចំនួន ២០ នាក់ដែលត្រូវបានបញ្ជូនត្រលប់ដោយរដ្ឋភាគីទៅកាន់ប្រទេសផ្សេងៗទៀត[14] ហើយនឹងសូមចង្អុលបង្ហាញពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឲ្យមានឡើង ដើម្បីតាមដានស្ថានភាពរបស់ពួកគេ។

មាត្រា ១០

២២. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថា-ខណ្ឌ ២៥) សូមផ្តល់នូវពត៌មានពាក់ព័ន្ធទៅនឹង៖

(ក) វិធានការនានាដែលត្រូវបានចាត់ឲ្យមានឡើង ដើម្បីបង្កើត និងពង្រឹងកម្មវិធីអប់រំ និងវគ្គបណ្តុះបណ្តាល រួមមានកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងការធានាថា គ្រប់មន្ត្រីទាំងអស់ដែលធ្វើការងារពាក់ព័ន្ធជាមួយជនជាប់ឃុំ រាប់ទាំងមន្ត្រីប្រតិបត្តិច្បាប់ មន្ត្រីពន្ធនាគារ ចៅក្រម និងព្រះរាជអាជ្ញា ត្រូវមានការយល់ដឹងជ្រៅជ្រះពីបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។[15]

(ខ) ការណែនាំពីសិទ្ធិមនុស្ស និងវគ្គបណ្តុះបណ្តាលសំរាប់បុគ្គលិកវេជ្ជសាស្ត្រ និងបុគ្គលិកសុខាភិបាលផ្សេងៗទៀតធ្វើការងារពាក់ព័ន្ធជាមួយជនជាប់ឃុំ ស្តីពីគោលការណ៍ណែនាំសម្រាប់

[14] A/HRC/13/39/Add.1 កថាខ័ណ្ឌ ១៩។ CERD/C/KHM/CO/8-13 កថាខ័ណ្ឌ ១៩។ CAT/C/SR.967 កថាខ័ណ្ឌ ២២។ CAT/C/SR.968 កថាខ័ណ្ឌ ៥ និង ៣៨។

[15] A/HRC/13/4 កថាខ័ណ្ឌ ៨២.១៥។ A/HRC/18/47 កថាខ័ណ្ឌ ២៦។

ស៊ើបរកសញ្ញានៃការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនស្របតាមបទដ្ឋានអន្តរជាតិ (Istanbul Protocol) ក៏ដូចជាសម្រាប់អ្នកមានវិជ្ជាជីវៈខាងផ្លូវចិត្ត ដែលធ្វើការជាមួយជនរងគ្រោះពីអំពើទារុណកម្ម និងសាក្សីទាំងនៅក្នុងតុលាកាសាមញ្ញ និងអង្គជំនុំជម្រះវិសាមញ្ញ។

(គ) ចំណាត់ការដើម្បីវាយតម្លៃទៅលើប្រសិទ្ធភាព និងការប្រែប្រួលពីវគ្គបណ្តុះបណ្តាល និងកម្មវិធីអប់រំទាំងនេះ។

មាត្រា ១១

២៣. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៥) សូមផ្តល់ព័ត៌មានស្តីពីវិធានការនានា ដែលបានចាត់ឲ្យមានឡើងដើម្បីពិនិត្យមើលប្រព័ន្ធវិន័យ និងការអនុវត្តន៍នៅក្នុងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែដើម្បីធានាថា ការដាក់វិន័យទៅលើអ្នកទោសដែលបានល្មើសច្បាប់ ឬវិន័យក្នុងពន្ធនាគារ ជាពិសេសក្នុងករណីលួចរត់ ឬការប៉ុនប៉ងលួចរត់ចេញពីពន្ធនាគារ ត្រូវអនុវត្តតាមការហាមឃាត់ដ៏ម៉ឺងម៉ាត់មិនឲ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីមកលើខ្លួនដែលមានចែងក្នុងមាត្រា ២៥ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១។

២៤. សូមផ្តល់ព័ត៌មានទាក់ទងទៅនឹង៖

(ក) វិធានការនានាដែលបានចាត់ឲ្យមានឡើង ក្នុងការបង្កើតប្រព័ន្ធថ្នាក់ជាតិមួយ ដែលអាចឃ្លាំមើលដោយមានប្រសិទ្ធភាព និងជាលក្ខណៈប្រព័ន្ធនៅគ្រប់ទីកន្លែង ដែលត្រូវបានដកហូតសេរីភាព រួមមានអង្គភាពនគរបាល ពន្ធនាគារ មណ្ឌលសង្គមកិច្ច មជ្ឈមណ្ឌលបន្សាបសារធាតុញៀន ដើម្បីធានាឲ្យមានការតាមដានមើលឲ្យបានត្រឹមត្រូវ នូវអនុសាសន៍ទាំងឡាយរបស់អ្នកឃ្លាំមើល។

(ខ) ចំនួននៃការធ្វើទស្សនកិច្ចពិនិត្យមើលទីកន្លែងឃុំខ្លួន ដោយស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធ ក៏ដូចជាអ្នកឃ្លាំមើលឯករាជ្យថ្នាក់ជាតិ និងអន្តរជាតិ រួមមានអង្គការមិនមែនរដ្ឋាភិបាល ដោយបែងចែកទៅតាមទីកន្លែងឃុំខ្លួន ហើយថាតើការចុះទស្សនកិច្ចទាំងនោះ ត្រូវបានប្រកាសឲ្យដឹងជាមុន ឬយ៉ាងណា។ សូមបញ្ជាក់ថាតើទស្សនកិច្ចទាំងនោះ មានរាប់បញ្ចូលកិច្ចសម្ភាសន៍ដោយសម្ងាត់ជាមួយជនជាប់ឃុំដែរ ឬយ៉ាងណា។

២៥. សូមផ្តល់នូវទិន្នន័យពីចំនួន៖

(ក) បុគ្គលជាប់ឃុំរង់ចាំសវនាការ និងបុគ្គលជាប់ឃុំរង់ចាំបណ្តឹងឧទ្ធរណ៍ ហើយនឹងចំនួនសរុបនៃជនជាប់ឃុំក្នុងពន្ធនាគារ នៅអំឡុងពេលកំពុងធ្វើរបាយការណ៍ ដោយបែងចែកទៅតាមយេនឌ័រ ព្រមទាំងស្ថិតិផ្ទះបញ្ចាំងនូវសមត្ថភាពផ្ទុក (ចំណុះ) និងចំនួនមនុស្ស ដែលត្រូវបានឃុំខ្លួននៅតាមទីកន្លែងឃុំខ្លួននីមួយៗនៅក្នុងរដ្ឋភាគី។

(ខ) បុគ្គលកំពុងត្រូវបានឃាត់ខ្លួននៅតាមទីកន្លែងផ្សេងៗទៀត ដែលសេរីភាពរបស់ពួកគេត្រូវបានដកហូត រួមមានអង្គភាពនគរបាល មណ្ឌលសង្គមកិច្ច មជ្ឈមណ្ឌលបន្សាបគ្រឿងញៀន និងមន្ទីរអន្តោប្រវេសន្ត ដោយបែងចែកទៅតាមយេនឌ័រ និងប្រភេទនៃមន្ទីរ/មណ្ឌលទាំងនោះ។

២៦. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៩) ពាក់ព័ន្ធទៅនឹងភាពចង្អៀតណែនយ៉ាងធ្ងន់ធ្ងរនៅតាមទីកន្លែងឃុំខ្លួន និងរបាយការណ៍ទាក់ទងទៅនឹងភាពគ្មានអនាម័យ ម្ហូបអាហារមិនគ្រប់គ្រាន់ និងការថែទាំសុខភាព សូមផ្តល់ព័ត៌មានស្តីពីវិធានការដែលបានចាត់ឲ្យមានឡើង ក្នុងការធ្វើឲ្យស្ថានភាពនៃការឃុំខ្លួនមានភាពប្រសើរឡើង និងសូមបញ្ជាក់ប្រសិនបើរដ្ឋភាគីបាន៖

(ក) អនុម័តច្បាប់ដែលអនុញ្ញាតិឲ្យមាននូវជម្រើសផ្សេងក្រៅពីការឃុំខ្លួន ដូចជាការដោះលែងដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យមុនពេលសវនាការ (ការត្រួតពិនិត្យតាមផ្លូវតុលាការ) ឬទោសការងារសហគមន៍ និងចំនួនបុគ្គលដែលត្រូវបានដាក់ក្រោមវិធានការមិនឃុំខ្លួន នៅអំឡុងពេលកំពុងធ្វើរបាយការណ៍។

(ខ) អភិវឌ្ឍន៍ និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនៃទីកន្លែងឃុំខ្លួន និងអនុម័តនូវបទដ្ឋានដែលពាក់ព័ន្ធ។

(គ) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពពន្ធនាគារទាក់ទងនឹងភាពអនាម័យ និងការផ្គត់ផ្គង់នូវម្ហូបអាហារ[16]។

(ឃ) ធ្វើឲ្យប្រសើរឡើងនូវសិទ្ធិទទួលបានការថែទាំសុខភាពសម្រាប់ជនជាប់ឃុំ ព្រមទាំងជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីដែលទើបនឹងសម្រាលកូនរួច។

[16] A/HRC/18/47 ផ្នែក II ស្តីពីការគាំទ្រដល់កំណែទម្រង់ពន្ធនាគារ កថាខ័ណ្ឌ ៨ - ១៨។

(ង) ចាត់វិធានការនានាដើម្បីបិទទ្វារពន្ធនាគារបណ្តោះអាសន្ននៅខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ និងជៀសវាងមិនប្រើប្រាស់ពន្ធនាគារប្រហាក់ប្រហែល ដែលមានកំរិតទាបជាងបទដ្ឋានក្នុងពេលអនាគត។

(ច) លើកឡើងនូវរបាយការណ៍ស្តីពីទម្លាប់អនុវត្តន៍ដោយនគរបាល ឬកងរាជអាវុធហត្ថមួយចំនួន ដែលធ្វើការឃុំ/ឃាត់ខ្លួននៅក្នុងទ្រុងតូចបណ្តោះអាសន្ននូវបុគ្គល ដែលត្រូវបានចាប់ខ្លួនដោយរង់ចាំការផ្ទេរទៅកាន់ទីកន្លែងឃុំខ្លួនដែលប្រសើរជាងនេះ។

២៧. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើការព្រួយបារម្ភ ដែលបានបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន ចំពោះរបាយការណ៍ស្តីពីការរំលោភបំពានទៅលើអ្នកទោសពីសំណាក់ "គណៈកម្មាធិការស្វ័យគ្រប់គ្រងពន្ធនាគារ" (កថាខណ្ឌទី១៩) សូមផ្តល់ទិន្នន័យស្តីពីករណីចោទប្រកាន់ពីការរំលោភបំពានពីអ្នកទោសទៅលើអ្នកទោសដូចគ្នា ដែលត្រូវបានស៊ើបអង្កេតដោយអាជ្ញាធរនៅអំឡុងពេលកំពុងធ្វើរបាយការណ៍ ជាពិសេសករណីរំលោភបំពានដោយអ្នកទោស ដែលត្រូវបានផ្តល់ឲ្យនូវការទទួលខុសត្រូវពីអាជ្ញាធរពន្ធនាគារ ចំនួនករណីដែលត្រូវបានផ្តន្ទាទោសខាងព្រហ្មទណ្ឌ ឬការដាក់ទោសផ្សេងៗទៀត ហើយនឹងទោសដែលជននោះទទួល។ សូមពិពណ៌នាផងដែរនូវករណីទាំងឡាយណា ដែលមន្ត្រីរាជការត្រូវបានដាក់ឲ្យទទួលរងទណ្ឌកម្មខាងវិន័យ ឬទណ្ឌកម្មខាងព្រហ្មទណ្ឌក្នុងការអនុគ្រោះ ឬបណ្តោយឲ្យមានការរំលោភបំពានបែបនេះ។

២៨. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើការព្រួយបារម្ភ ដែលបានបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន ទាក់ទងនឹងការចោទប្រកាន់ទាំងឡាយពីអំពើហិង្សាផ្លូវភេទនៅតាមទីកន្លែងឃុំខ្លួន សូមផ្តល់នូវៈ

(ក) ទិន្នន័យទាក់ទងទៅនឹងឧប្បត្តិហេតុនៃអំពើហិង្សាផ្លូវភេទនៅតាមទីកន្លែងឃុំខ្លួន ដែលបានចងក្រងទុកជាឯកសារចាប់តាំងពីបានពិនិត្យរបាយការណ៍ចុងក្រោយ ដោយបែងចែកទៅតាមទីកន្លែងឃុំខ្លួន និងស្ថានភាពនៃការស៊ើបអង្កេតទៅលើករណីទាំងនេះ។

(ខ) វិធានការនានាដែលបានចាត់ឲ្យមានឡើង ដើម្បីធានាការឃុំខ្លួនជនជាប់ឃុំជាស្ត្រី ដាច់ដោយឡែកពីជនជាប់ឃុំជាបុរស ហើយនឹងដើម្បីធានាថាជនជាប់ឃុំជាស្ត្រី ត្រូវបានយាមការពារដោយស្ត្រី។

២៩. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៩) សូមផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពអំពីចំនួនមរណភាពនៅអំឡុងពេលឃុំ/ឃាត់ខ្លួន ដោយរួមបញ្ចូលទាំងមរណភាពរបស់ជនជាប់ឃុំនៅតាមមន្ទីរពេទ្យ ចាប់តាំងពីបានពិនិត្យរបាយការណ៍ចុងក្រោយ ដោយបែងចែកទៅតាម មូលហេតុនៃការស្លាប់ ហើយសូមបញ្ជាក់ប្រសិនបើមានមន្ត្រីណាមួយត្រូវបានស៊ើបអង្កេត ចោទប្រកាន់ និងត្រូវបានផ្តន្ទាទោសដោយសារមានពាក់ព័ន្ធនឹងមរណភាពទាំងនេះ ជាពិសេសពាក់ព័ន្ធទៅនឹងករណីមរណភាពរបស់ គង់ ឡា ហេង ទូច និង ម៉ៅ សុខ។[17]

**មាត្រា ១២ និង ១៣**

៣០. ដោយកត់សម្គាល់ឃើញពីការព្រួយបារម្ភ ដែលបានបង្ហាញដោយគណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ១៥ និង១៦) ទាក់ទងទៅនឹងរបាយការណ៍ទាំងឡាយស្តីពីការរីករាលដាលនៃការធ្វើទារុណកម្មដោយមន្ត្រីប្រតិបត្តិច្បាប់ រាប់ទាំងការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទទៅលើស្ត្រីនៅតាមទីកន្លែងឃុំខ្លួន និងការមិនបានស៊ើបអង្កេត និងការមិនបានផ្តន្ទាទោសទៅលើករណីទាំងនេះ ព្រមទាំងមិនមានស្ថាប័នស៊ីវិលសម្រាប់ត្រួតពិនិត្យមើលដោយឯករាជ្យ ដើម្បីទទួល និងធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងនោះ សូមផ្តល់នូវ៖

(ក) ទិន្នន័យស្ថិតិអំពីពាក្យបណ្តឹងទាំងអស់ដែលបានទទួល ពាក់ព័ន្ធទៅនឹងការធ្វើទារុណ-កម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយមន្ត្រីប្រតិបត្តិច្បាប់ នៅពេលកំពុងធ្វើរបាយការណ៍ ដោយបែងចែកទៅតាមស្ថាប័នទទួលពាក្យបណ្តឹង និងបទល្មើសដែលបានចោទប្រកាន់ ព្រមទាំងព័ត៌មានអំពីការស៊ើបអង្កេត ការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ឬខាងវិន័យទៅលើចារី។

(ខ) ព័ត៌មានស្តីពីការអនុវត្តន៍មាត្រា ២៨ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១ ទាក់ទងទៅនឹងបណ្តឹងតវ៉ារបស់ជនជាប់ឃុំ រួមមានចំនួន និងប្រភេទពាក្យបណ្តឹងដែលបានទទួល ព្រមទាំងព័ត៌មានទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ឬខាងវិន័យទៅលើចារី។

៣១. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថា - ខណ្ឌ ១៦) ហើយនឹងការទទួលយករបស់រដ្ឋភាគីនូវអនុសាសន៍នានា ដែលបានធ្វើឡើងនៅពេលកំពុងពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមកាលកំណត់ (A/HRC/13/4 កថាខណ្ឌ ៨២.២៧) សូម

[17] CAT/C/SR.967 កថាខ័ណ្ឌ ១៧។

ផ្តល់នូវព័ត៌មានអំពីវិធានការនានាដែលបានចាត់ឲ្យមានឡើង ដើម្បីធានាឲ្យមានការស៊ើបអង្កេតជាបន្ទាន់ មិនលម្អៀង និងប្រកបដោយប្រសិទ្ធភាពទៅលើការចោទប្រកាន់ទាំងឡាយ ពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ហើយនឹងនាំខ្លួនមកកាត់ទោសចំពោះមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារទាំងឡាយណា ដែលបានប្រព្រឹត្ត បញ្ជាឲ្យប្រព្រឹត្ត ឬព្រមព្រៀង/យល់ព្រមចំពោះការប្រព្រឹត្តបែបនេះ។ សូមបញ្ជាក់ប្រសិនបើជនសង្ស័យទាំងឡាយ ក្នុងករណីប្រព្រឹត្តទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ត្រូវបានព្យួរការងារ ឬតែងតាំងការងារជាថ្មី ក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត ថាតើមានយន្តការឯករាជ្យណាមួយ ដើម្បីទទួលពាក្យបណ្តឹងពីការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ដែលប្រព្រឹត្តដោយមន្ត្រីប្រតិបត្តិច្បាប់ដែរ ឬយ៉ាងណា ប្រសិនបើមាន សូមបញ្ជាក់ពីចំនួនពាក្យបណ្តឹងដែលបានទទួល និងចំណាត់ការដែលបានចាត់ឲ្យមានឡើង ដើម្បីឆ្លើយតបទៅនឹងបណ្តឹងទាំងនោះ។

មាត្រា ១៤

៣២. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២៦) សូមផ្តល់នូវព័ត៌មានអំពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងវិធានការដំណោះស្រាយ និងការជួសជុលសំណងជាប្រាក់ ព្រមទាំងវិធានការផ្សេងៗទៀត រួមមានមធ្យោបាយស្តារនីតិសម្បទា ដែលបង្គាប់ដោយតុលាការ ហើយនឹងបានផ្តល់ដល់ជនរងគ្រោះពីអំពើទារុណកម្ម ចាប់តាំងពីបានពិនិត្យរបាយ-ការណ៍តាមកាលកំណត់លើកចុងក្រោយ។ ព័ត៌មាននេះគួរតែរួមបញ្ចូលទាំងចំនួនសំណើដែលបានធ្វើ ចំនួនសំណើដែលបានសម្រេចឲ្យ បរិមាណនៃសំណងដែលបង្គាប់ដោយតុលាការ ហើយនឹងសំណងដែលបានផ្តល់ជាក់ស្តែងក្នុងករណីនីមួយៗ ព្រមទាំងឧទាហរណ៍នៃសេចក្តីសម្រេចដោយអាជ្ញាធរមានសមត្ថកិច្ចដែលបង្គាប់ឲ្យបង់សំណង។ សូមផ្តល់ផងដែរនូវព័ត៌មានស្តីពីភាពអាចទទួលបាន និងអត្ថិភាពនៃកម្មវិធីស្តារនីតិសម្បទា សម្រាប់ជនរងគ្រោះពីអំពើទារុណកម្ម ប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអំពើហិង្សាផ្លូវភេទផ្សេងៗទៀត រួមមានជំនួយខាងវេជ្ជសាស្ត្រ និងខាងផ្លូវចិត្ត។[18]

៣៣. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២៨) សូមផ្តល់ព័ត៌មានអំពីការផ្តល់សំណងជួសជុលដោយរដ្ឋភាគី ដល់ជនរងគ្រោះពីអំពើទារុណកម្មដែលស្ថិតនៅក្នុងសម័យខ្មែរក្រហម។ តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត

[18] CRC/C/KHM/CO/2-3កថាខ័ណ្ឌ ៣៩ ។ CAT/C/SR.967កថាខ័ណ្ឌ ៥៥។ CAT/C/SR.968 កថាខ័ណ្ឌ ៥២។

.ក) មានបានធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុងរបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យមានការជួសជុលសំណង រួមមានសំណងជាទឹកប្រាក់ជាលក្ខណៈបុគ្គល ដល់ជនរងគ្រោះស្របតាមមាត្រា ១៤ នៃអនុសញ្ញានេះដែរ ឬទេ?[19] ប្រសិនបើគ្មានទេនោះ តើមានវិធានការអ្វីដែលនឹងត្រូវចាត់ឲ្យមានឡើង ដើម្បីធានាថា ជនរងគ្រោះពីអំពើទារុណកម្ម រួមមានទារុណកម្មលើយែនឌ័រ ដែលកើតឡើងក្នុងអំឡុងសម័យខ្មែរក្រហម ត្រូវទទួលសំណងស្របតាមអនុសញ្ញានេះដែរ ឬទេ? តើមានចំណាត់ការអ្វីខ្លះដែលបានអនុវត្តន៍រួចហើយ ដើម្បីពង្រឹងការគាំទ្រដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនៅអំឡុងពេលដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសដល់អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងនឹងការគាំទ្រផ្នែកច្បាប់ និងផ្នែកចិត្តសាស្ត្រសង្គម។

## មាត្រា ១៥

៣៤. គណៈកម្មាធិការបានបង្ហាញការព្រួយបារម្ភកាលពីលើកមុនហើយថា (កថាខណ្ឌ ២៨) ការប្រើប្រាស់ចម្លើយសារភាពបែបនេះ ធ្វើជាភស្តុតាងក្នុងនីតិវិធីតុលាការគឺមានការរីករាលដាល។ សូមបង្ហាញព័ត៌មានអំពីវិធានការនានា ដែលបានចាត់ឲ្យមានឡើងដើម្បីធានាថា តាមការអនុវត្តន៍ជាក់ស្តែងចម្លើយដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវយកមកប្រើធ្វើជាភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែយកចម្លើយនោះមកប្រើជាភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ ពីបទប្រព្រឹត្តអំពើទារុណកម្ម។ សូមចង្អុលបង្ហាញ (ក) ថាតើមានមន្ត្រីរាជការណាមួយត្រូវបានចោទប្រកាន់ និងផ្តន្ទាទោស ដោយសារការជំរិតយកចម្លើយសារភាពបែបនេះដែរ ឬយ៉ាងណា ព្រមទាំងឧទាហរណ៍ពីករណីដែលជនជាប់ចោទប្តឹងថា ចម្លើយសារភាពរបស់ខ្លួនត្រូវបានធ្វើដោយបង្ខិតបង្ខំ និង (ខ) ថាតើតុលាការមានបានរកឃើញករណីណាមួយពីការផ្តន្ទាទោសដោយមិនត្រឹមត្រូវ ផ្អែកលើភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ហើយមានបានផ្តល់សំណងដល់ជនរងគ្រោះដែរ ឬយ៉ាងណា។

## មាត្រា ១៦

៣៥. បន្ទាប់ពីបានពិនិត្យពិចារណាទៅលើអនុសាសន៍របស់គណៈកម្មាធិការកាលពីលើកមុន (កថាខណ្ឌ ២០) ដែលបានបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន ទាក់ទងទៅនឹងការចោទប្រកាន់ទាំងឡាយអំពីការរំលោភបំពាន និងការឃុំខ្លួនតាមទំនើងចិត្តនៅតាមមណ្ឌលសង្គមកិច្ច មណ្ឌលស្តារយុវនីតិសម្បទា និងមជ្ឈមណ្ឌលបន្សាបសារជាតុញៀន[20] សូមផ្តល់នូវព័ត៌មានដូចខាងក្រោម៖

---

[19] A/HRC/15/46 កថាខ័ណ្ឌ ៣២ និង ៩៦។ CAT/C/SR.967 កថាខ័ណ្ឌ ១៦ ២៤ និង ៩៩។ A/HRC/13/4 កថាខ័ណ្ឌ ៨២.៩៣។
[20] A/HRC/18/47 កថាខ័ណ្ឌ ៩៨។

(ក) ទិន្នន័យអំពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសទៅលើមន្ត្រី កងការពារ/ឆ្មាំពន្ធនាគារ និងបុគ្គលផ្សេងៗទៀតនៅតាមទីកន្លែងឃុំខ្លួនទាំងនេះ ព្រមទាំងមជ្ឈមណ្ឌលបន្សាបសារធាតុញៀននានា ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការឃុំខ្លួនតាមទំនើងចិត្ត ឬការរំលោភបំពាន ដោយបញ្ជាក់ពីមុខងារ និងឋានន្តរស័ក្តិរបស់ជនត្រូវចោទ ពីបទចោទ និងការដាក់ទោសខាងវិន័យ ឬទោសព្រហ្មទណ្ឌ។

(ខ) ទិន្នន័យអំពីការជួសជុលសំណងទាំងឡាយ រួមមានសំណងជាទឹកប្រាក់ និងការស្តានីតិសម្បទា ដែលត្រូវផ្តល់ដល់ជនរងគ្រោះពីការឃុំខ្លួនតាមទំនើងចិត្ត និងការរំលោភបំពាននៅតាមមណ្ឌលទាំងនេះ។

(គ) ប្រសិនបើរដ្ឋភាគីបានធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់ពីបទរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ រួមមានការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការវាយដំ និងការសម្លាប់ជនជាប់ឃុំដោយឆ្មាំសន្តិសុខនៅក្នុងមណ្ឌលសង្គមកិច្ចព្រៃស្ពឺក្នុងចន្លោះឆ្នាំ ២០០៦ - ២០០៨ តើបានលទ្ធផលយ៉ាងដូចម្តេច?

(ឃ) ថាតើរដ្ឋភាគីមានបានបង្កើតនូវជម្រើសផ្សេងៗប្រកបដោយមនុស្សធម៌ និងមាននិរន្តរ - ភាពក្រៅពីមណ្ឌលទាំងនេះ សម្រាប់ក្រុមមនុស្សដែលមិនបានទទួលផលប្រយោជន៍ពីសង្គម និងក្រុមមនុស្សងាយរងគ្រោះនៅក្នុងមណ្ឌលទាំងនេះ ឬយ៉ាងណា។

(ង) អត្រានៃការរស់នៅក្នុងមណ្ឌល រួមមានចំនួនអនីតិជន ស្ត្រី ជនវិកលចរិត ជនផ្ទុកមេរោគអេដស៍ អ្នកជម្ងឺរបេង ដែលត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលសង្គមកិច្ច មណ្ឌលស្តារយុវនីតិសម្បទា និងមណ្ឌលបន្សាបសារធាតុញៀនទាំងអស់នៅក្នុងរដ្ឋភាគី។

៣៦. សូមផ្តល់នូវទិន្នន័យ (ក) អំពីករណីទាំងឡាយ ដែលមន្ត្រីប្រតិបត្តិច្បាប់ត្រូវបានដាក់ទោសខាងវិន័យ ឬទោសព្រហ្មទណ្ឌ ដោយសារការប្រើប្រាស់កម្លាំងហួសប្រមាណ ឬប្រព្រឹត្តកម្មមិនគប្បីទៅលើបាតុករ និង (ខ) អំពីស្ថានភាពនៃការស៊ើបអង្កេតទាំងឡាយ និងការដាក់ទោសខាងវិន័យ ឬទោសព្រហ្មទណ្ឌទៅលើមន្ត្រីប្រតិបត្តិច្បាប់ ឬបុគ្គលិកយោធា ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ដូចខាងក្រោមៈ

(ក) សេចក្តីរាយការណ៍អំពីការវាយដំចំនួន ២ លើកដោយមន្ត្រីនគរបាលទៅលើអ្នកការពារសិទ្ធិមនុស្សឈ្មោះ សួង សោភ័ណ្ឌ។

(ខ)	សេចក្តីរាយការណ៍អំពីការប្រើប្រាស់កងកម្លាំង និងគ្រាប់កាំភ្លើងពិតក្នុងពេលបណ្តេញប្រជាពលរដ្ឋចំនួនប្រហែលជា ៣០០ គ្រួសារចេញពីសហគមន៍បុរីកីឡាដោយបង្ខំនៅរាជធានីភ្នំពេញនៅថ្ងៃទី ៣ ខែមករាឆ្នាំ ២០១២។

(គ)	ការប្រើប្រាស់កងកម្លាំង និងគ្រាប់កាំភ្លើងពិតដោយឆ្មាំសន្តិសុខឯកជនប្រដាប់ដោយអាវុធរបស់ក្រុមហ៊ុន TTY ដែលត្រូវបានរាយការណ៍មកថាបានបាញ់អ្នកតវ៉ាចំនួន ៤ នាក់នៅថ្ងៃទី ១៨ ខែមករាឆ្នាំ ២០១២ នៅភូមិវាលបី ស្រុកស្នួល ខេត្តក្រចេះនៅពេលកំពុងធ្វើការតវ៉ាដោយអ្នកភូមិ ដើម្បីរារាំងការបំផ្លិចបំផ្លាញដំណាំរបស់ពួកគេ ដោយម៉ាស៊ីនឈូសដីរបស់ក្រុមហ៊ុនឯកជននេះ។

(ឃ)	សេចក្តីរាយការណ៍អំពីការបណ្តេញចេញអ្នកភូមិដោយបង្ខំ ដោយបុគ្គលិកសន្តិសុខប្រដាប់ដោយអាវុធនៅខេត្តក្រចេះនៅថ្ងៃទី ១៦ ខែឧសភាឆ្នាំ ២០១២ ដែលក្នុងនោះក្មេងស្រីម្នាក់ឈ្មោះ ហេង ចន្ថា អាយុ១៤ ឆ្នាំបានស្លាប់ដោយត្រូវគ្រាប់កាំភ្លើង។

(ង)	សេចក្តីរាយការណ៍អំពីការប្រើប្រាស់កម្លាំងដោយមន្ត្រី ក្នុងការឆ្លើយតបទៅនឹងការធ្វើបាតុកម្មដោយសន្តិវិធីដោយកម្មកររោងចក្រនៅក្រុងបាវិត ខេត្តស្វាយរៀងនៅថ្ងៃទី ២០ ខែកុម្ភៈឆ្នាំ ២០១២ រាប់ទាំងការបាញ់កាំភ្លើងទៅលើកម្មការិនីចំនួន ៣ នាក់ផង។

(ច)	សេចក្តីរាយការណ៍អំពីការប្រើប្រាស់កម្លាំងហួសប្រមាណ នៅក្រៅបរិវេណសាលាឧទ្ធរណ៍ក្នុងប្រទេសកម្ពុជានៅថ្ងៃទី ២៧ ខែមិថុនាឆ្នាំ ២០១២ ដោយមន្ត្រីនគរបាលទៅលើបាតុកររួមមានស្ត្រី និងកុមារដែលមកពីសហគមន៍បឹងកក់។

(ឆ)	សេចក្តីរាយការណ៍អំពីការវាយដំនឹងដំបងដោយមន្ត្រីនគរបាល ទៅលើសហជីពឈ្មោះ រ៉ុង បញ្ញា នៅរាជធានីភ្នំពេញនៅថ្ងៃទី ១១ ខែកក្កដាឆ្នាំ ២០១២ ខណៈដែលគាត់កំពុងចូលរួមក្នុងការដើរជាក្បួនដោយសន្តិវិធីជាមួយនឹងកម្មកររោងចក្រចំនួន ២០ នាក់ផ្សេងទៀតមកពីសហព័ន្ធសហជីពកម្ពុជា (CCU)។ បន្ទាប់ពីត្រូវបានកងកម្លាំងមន្ត្រីនគរបាលវាយដំឲ្យរងរបួសរួចមក គាត់ត្រូវបានគេនាំយកទៅឃុំខ្លួនតាមទំនើងចិត្តអស់រយៈពេល ១២ ម៉ោង នៅក្នុងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដោយមិនទទួលបានការព្យាបាលខាងវេជ្ជសាស្ត្រឡើយ។

៣៧. បន្ទាប់ពីបានពិនិត្យអនុសាសន៍នានាដោយគណៈកម្មាធិការ (កថាខ័ណ្ឌ ២៣) និងគណៈកម្មាធិការស្តីពីសិទ្ធិកុមារ (CRC/C/KHM/CO/2-3 កថាខ័ណ្ឌ ៧៧) សូមផ្តល់ព័ត៌មានអំពី:

(ក) ចំនួនអនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលត្រូវបានដកហូតសេរីភាពនៅក្នុងរដ្ឋភាគី បំបែកតាមយេនឌ័រ និងតាមទីកន្លែងឃុំខ្លួន។

(ខ) រដ្ឋភាគីបានបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនដោយឡែកមួយ ដោយស្របទាំងស្រុងទៅនឹងបទដ្ឋានអន្តរជាតិនានា បើមិនដូច្នោះទេមានចេតនានឹងបង្កើតប្រព័ន្ធនេះ តាមអនុសាសន៍របស់គណៈកម្មាធិការ ឬយ៉ាងណា។

(គ) វិធានការទាំងឡាយជំនួសការឃុំខ្លួន ក្នុងគោលបំណងធ្វើឲ្យប្រាកដប្រជាថា ការដកហូតសេរីភាពអនីតិជន ត្រូវប្រើសំរាប់តែវិធានការចុងក្រោយ សម្រាប់រយៈពេលខ្លីបំផុត និងតាមលក្ខខ័ណ្ឌសមស្រប។

(ឃ) អនីតិជនត្រូវបានឃុំខ្លួនដាច់ដោយឡែកពីមនុស្សពេញវ័យ (មនុស្សចាស់)ឬយ៉ាងណា។

(ង) ចំនួនក្មេងស្នាក់នៅជាមួយឪពុកម្តាយរបស់ពួកគេ ដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ ដែលត្រូវបំបែកទៅតាមចំនួនអាយុ និងយេនឌ័រ។

៣៨. សូមផ្តល់ព័ត៌មានអំពីវិធានការទាំងឡាយ រាប់ទាំងវិធានការផ្លូវច្បាប់ផង ដែលត្រូវបានចាត់ឲ្យមានឡើងដើម្បីធ្វើឲ្យប្រាកដប្រជាថា អ្នកការពារសិទ្ធិមនុស្សទាំងអស់ អ្នកសារព័ត៌មាន និងសមាជិកសហជីពត្រូវបានការពារពីការបំភិតបំភ័យ ឬអំពើហិង្សា ជាពិសេសពីសំណាក់មន្រ្តីសន្តិសុខ និងមន្រ្តីប្រតិបត្តិច្បាប់ដោយសារតែការធ្វើសកម្មភាពរបស់ពួកគេ។ ជាពិសេសសូមធ្វើការពន្យល់អំពី:

(ក) ហេតុការណ៍ដែលសាលាដំបូងខេត្តកោះកុង បានដំកល់ទុកមិនចាត់ការនូវករណីសម្លាប់លោក ឈុត វុទ្ធី ក្រៅច្បាប់នៅថ្ងៃទី ២៦ខែមេសាឆ្នាំ ២០១២ ដូច្នេះនាំឲ្យរារាំងមិនឲ្យពិនិត្យចម្លើយសាក្សីបន្ថែម ដើម្បីកំណត់អត្តសញ្ញាណឃាតករ។

(ខ) ការកាត់ទោសលោក ម៉ម សូណង់ដូ ប្រធានស្ថានីយវិទ្យុសំបុកឃ្មុំ និងជាប្រធានសមាគមន៍អ្នកប្រជាធិបតេយ្យឲ្យជាប់ពន្ធនាគារ ២០ ឆ្នាំដោយចោទប្រកាន់គ្មានមូលដ្ឋានពីបទល្មើសព្រហ្មទណ្ឌនានា រាប់ទាំងបទល្មើស "កុបកម្ម" ផងនៅថ្ងៃទី១២ ខែកក្កដាឆ្នាំ ២០១២ បន្ទាប់ពីគាត់បានធ្វើសេចក្តីរាយការណ៍ស្តីពីការរឹបអូសយកដីធ្លី។

(គ) ការដាក់ពាក្យបណ្តឹងចោទប្រកាន់ក្នុងឆ្នាំ ២០១១ ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងលោក សួស ចាន់ថា ជាមេដឹកនាំសហជីពកម្មករ។

(ឃ) របាយការណ៍នានាចុះថ្ងៃទី ២៦ ខែកញ្ញាឆ្នាំ ២០១១[21] រាប់ទាំងរបាយកាណ៍ទាំងឡាយនៅក្នុងលិខិតអះអាងរបស់អ្នករាយការណ៍ពិសេសចំនួន ៥ រូបដែលថារដ្ឋភាគីបានព្យួរសកម្មភាពអង្គការក្រៅរដ្ឋាភិបាលមួយជាបណ្ដោះអាសន្ន ហើយថាមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីសន្តិសុខបានចេញសេចក្ដីប្រមាន ហើយនឹងចូលរួមក្នុងអំពើបំភិតបំភ័យជាច្រើនលើក ទៅលើអង្គការក្រៅរដ្ឋាភិបាលមួយចំនួនផ្សេងទៀត ដោយសារតែពួកគេបំពេញការងារខាងសិទ្ធិមនុស្សដោយផ្ទាល់ ទាក់ទងនឹងសិទ្ធិលំនៅដ្ឋានព្រមទាំងសិទ្ធិដីធ្លី។

(ង) ក្ដីកង្វល់នានាដែលសម្ដែងឲ្យដឹងពីអ្នករាយការណ៍ពិសេស ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ទាក់ទងនឹងការសងសឹកទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជនសិទ្ធិដីធ្លី និងបុគ្គលសហគមន៍ដែលការពារសិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លីរបស់ពួកគេក្នុងបរិបទជម្លោះដីធ្លី។[22]

៣៩. បន្ទាប់ពីបានពិនិត្យអនុសាសន៍នានា ដែលធ្វើឡើងដោយគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ (CERD/C/KHM/CO/8-13 កថាខ័ណ្ឌ ១៧) សូមបញ្ជាក់ប្រាប់នូវវិធានការដែលបានចាត់ឲ្យមានឡើង ដើម្បីធានាការការពារឲ្យបានពេញលេញដល់ជនជាតិដើមភាគតិច ពីការវាយប្រហារទៅលើរាងកាយ និងការបំភិតបំភ័យ ដោយសារតែពួកគេប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងការទាមទារដីសហគមន៍។

**បញ្ហាផ្សេងៗ**

៤០. សូមផ្ដល់ព័ត៌មានបច្ចុប្បន្នភាពស្ដីពីរបៀប ដែលរដ្ឋភាគីបានធានាថាវិធានការប្រឆាំងភេរវកម្ម ត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនទាំងអស់តាមអនុសញ្ញា អនុលោមតាមសេចក្ដីសម្រេចក្រុមប្រឹក្សាសន្តិសុខលេខ ១៦២៤ (២០០៥)។ សូមពិពណ៌នាចំនួន និងប្រភេទមនុស្សដែលត្រូវបានផ្ដន្ទាទោសតាមច្បាប់ កិច្ចធានាការពារតាមផ្លូវច្បាប់បែបនេះ និងដំណោះស្រាយជាសំណាងដល់មនុស្ស ដែលទទួលរងពីវិធានការប្រឆាំងភេរវកម្មតាមច្បាប់ និងតាមការអនុវត្តជាក់ស្ដែង ហើយនឹងវិធានការទាំងឡាយដែលបានចាត់ឲ្យមានឡើងពីរដ្ឋភាគី ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្ដឹងពីបទមិនគោរពបទដ្ឋានអន្តរជាតិ។

**ព័ត៌មានទូទៅស្ដីពីស្ថានភាពសិទ្ធិមនុស្សថ្នាក់ជាតិ រាប់ទាំងវិធានការថ្មីៗ និងការវិវត្តន៍ទាក់ទងនឹងការអនុវត្តអនុសញ្ញា**

[21] A/HRC/20/27/Add.3 កថាខ័ណ្ឌ ៥៦។ A/HRC/WG.6/6/KHM/3 កថាខ័ណ្ឌ ១៧។ CERD/C/KHM/CO/8-13 កថាខ័ណ្ឌ ១៧។ A/HRC/18/47 កថាខ័ណ្ឌ ២៥។

[22] A/HRC/18/46.

៤១. សូមផ្តល់ព័ត៌មានពិស្តារអំពីការវិវត្តន៍ពាក់ព័ន្ធថ្មីៗ ស្តីពីក្របខ័ណ្ឌច្បាប់ និងស្ថាប័នក្នុងសិទ្ធិមនុស្សណាខ្លះ ដែលត្រូវបានលើកស្ទួយ និងការពារនៅថ្នាក់ជាតិដែលបានកើតឡើង ចាប់តាំងពីមានរបាយការណ៍តាមកាលកំណត់ពីមុន រាប់ទាំងសេចក្តីសម្រេចជាយុត្តិសាស្ត្រពាក់ព័ន្ធផង។

៤២. សូមផ្តល់ព័ត៌មានពិស្តារពាក់ព័ន្ធស្តីពីវិធានការថ្មីតាមផ្លូវរដ្ឋបាល តាមផ្លូវនយោបាយ និងវិធានការផ្សេងៗទៀតដែលបានចាត់ឲ្យមានឡើង ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ ដែលបានកើតឡើងចាប់តាំងពីមានរបាយការណ៍តាមកាលកំណត់ពីមុន រាប់ទាំងព័ត៌មានស្តីពីផែនការ ឬកម្មវិធីសិទ្ធិមនុស្សថ្នាក់ជាតិ ព្រមទាំងធនធានសំរាប់ផែនការ ឬកម្មវិធីបែបនេះ មធ្យោបាយ គោលដៅ និងសំរាប់លទ្ធផលរបស់វា។

៤៣. សូមផ្តល់ព័ត៌មានផ្សេងៗទៀតស្តីពីវិធានការថ្មីៗ និងការវិវត្តន៍ទាំងឡាយដែលបានចាត់ឲ្យមានឡើង ដើម្បីអនុវត្តអនុសញ្ញា និងអនុសាសន៍នានារបស់គណៈកម្មាធិការ ចាប់តាំងពីបានពិនិត្យរបាយ-ការណ៍តាមកាលកំណត់ពីមុនក្នុងឆ្នាំ ២០១០ រាប់ទាំងទិន្នន័យស្ថិតិដែលចាំបាច់ ព្រមទាំងព័ត៌មានស្តីពីព្រឹត្តិការណ៍ ដែលបានកើតឡើងក្នុងរដ្ឋភាគី ហើយនឹងមានពាក់ព័ន្ធតាមអនុសញ្ញា។